# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ២០១៥

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ២៦៨,២៤៨ ដុល្លារអាមេរិក សម្រាប់ការស្តារប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តពោធិ៍សាត់ និងខេត្តព្រៃវែង និងការសាងសង់ទីស្នាក់ការក្នុងខេត្តពោធិ៍សាត់

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន២៦៨,២៤៨ ដុល្លារអាមេរិក ដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់ និងខេត្តព្រៃវែង និងខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបីសម្រាប់គម្រោងដូចតទៅ៖

**១. <u>គម្រោងស្តារប្រព័ន្ធធារាសាស្ត្រអន្លង់រូង ក្នុងខេត្តពោធិ៍សាត់ (ថវិកាចំនួន៨៩,៧៧៥ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់</u>

គម្រោងទីមួយនេះ គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រព ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានថវិកាសរុបចំនួន ៨៩,៧៧៥ ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយរង១ខ្សែប្រវែង ២,១០០ម៉ែត្រ ការសាងសង់សំណង់ក្បាលប្រឡាយរង១កន្លែង សំណង់លូជ្រុង១កន្លែង និងសំណង់លូបញ្ចេញទឹក៣កន្លែង។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាកសិករប្រមាណជា ១,៥០០នាក់ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

**២. <u>គម្រោងស្តារឡើងវិញប្រឡាយរងស្តៅ ក្នុងខេត្តព្រៃវែង (ថវិកាចំនួន ៨៩,៤២៣ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង</u>

គម្រោងទីពីរនេះ គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រព ក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ដែលមានថវិកាសរុបចំនួន ៨៩,៤២៣ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយរង១ខ្សែប្រវែង ២,២៥០ម៉ែត្រ ការសាងសង់សំណង់បញ្ចូលទឹក១កន្លែង សំណង់ស្នាក់ទឹក១កន្លែង និងសំណង់លូរំដោះទឹក២កន្លែង។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាកសិករប្រមាណជា ១,០០០នាក់ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

**៣. <u>គម្រោងសាងសង់ទីស្នាក់ការអភិរក្សតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាលក្នុងខេត្តពោធិ៍សាត់ (ថវិកាចំនួន ៨៩,០៥០ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ ខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់</u>

គម្រោងទីបីនេះ គឺដើម្បីផ្តល់ទីស្នាក់ការអភិរក្សតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាលក្នុងខេត្តពោធិ៍សាត់ ដល់ខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់។ យើងក៏សង្ឃឹមថាគម្រោងនេះ នឹងផ្តល់ជូននូវទីស្នាក់ការយាមល្បាតមួយខ្នង២ជាន់ ដែលមាន១០បន្ទប់ ។ ទីស្នាក់ការនេះ នឹងជួយពង្រឹងនៃការយាមល្បាតពីការកាប់ព្រៃឈើខុសច្បាប់ ហើយនឹងផ្តល់អត្ថប្រយោជន៍ជូនដល់ប្រជាពលរដ្ឋដែលរស់នៅពឹងអាស្រ័យផល អនុផលព្រៃឈើ ប្រមាណជា៥,៤០០គ្រួសារផងដែរ។

*ជំនួយឥតសំណង គូសាណូណិ របស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៤លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៤០ គម្រោង ។

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីម៉ែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*